**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:១៣ សសរ**

27-02-11

# សេចក្តីសម្រេច

## ស្តីពីការបង្កើតក្រុមការងារសម្របសម្រួល ជាមួយក្រុមអ្នកសង្កេតការណ៍ឥណ្ឌូនេស៊ីមកត្រួតពិនិត្យបទឈប់បាញ់

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស / រកត / ០៩០៨ / ១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមតម្រូវការការងារចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ ១** : ត្រូវបានបង្កើតក្រុមការងារសម្របសម្រួលជាមួយក្រុមសង្កេតការណ៍ឥណ្ឌូនេស៊ីមកត្រួតពិនិត្យបទឈប់បាញ់គ្នា ដូចមានសមាសភាពខាងក្រោម ÷

១- ឯកឧត្តមនាយឧត្តមសេនីយ៍ **ទៀ បាញ់** រដ្ឋមន្ត្រីក្រសួងការពារជាតិ ប្រធាន

២- ឯកឧត្តម **អ៊ុក រ៉ាប៊ុន** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

៣- ឯកឧត្តម **ប្រាក់ សុខុន** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

៤- ឯកឧត្តមនាយឧត្តមសេនីយ៍ **នាង ផាត** រដ្ឋលេខាធិការក្រសួងការពារជាតិ សមាជិក

៥- ឯកឧត្តម **ឡុង វិសាលោ** រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សមាជិក

៦- ឯកឧត្តមនាយឧត្តមសេនីយ៍ **នេត សាវឿន** អគ្គស្នងការនគរបាលជាតិ សមាជិក

៧- ឯកឧត្តមនាយឧត្តមសេនីយ៍ **គន់ គីម** អគ្គមេបញ្ជាការរងកងយោធពលខេមរភូមិន្ទ សមាជិក

៨- ឯកឧត្តមនាយឧត្តមសេនីយ៍ **ហ៊ីង ប៊ុនហៀង** អគ្គមេបញ្ជាការរងកងយោធពលខេមរភូមិន្ទ មេបញ្ជាការបញ្ជាការដ្ឋានអង្គរក្ស សមាជិក

៩- ឯកឧត្តមនាយឧត្តមសេនីយ៍ **សៅ សុខា** អគ្គមេបញ្ជាការរងកងយោធពលខេមរភូមិន្ទ មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស សមាជិក

**ប្រការ ២** : ក្រុមការងារនេះមានភារកិច្ចសម្របសម្រួល និងផ្តល់លក្ខណៈងាយស្រួលគ្រប់បែបយ៉ាងដល់ការបំពេញភារកិច្ចរបស់ក្រុមអ្នកសង្កេតការណ៍ឥណ្ឌូនេស៊ី ស្របតាមលក្ខខណ្ឌប្រតិបត្តិរបស់ក្រុមនេះ ។

**ប្រការ ៣** : ក្រុមការងារត្រូវរាយការណ៍ជូនសម្តេចនាយករដ្ឋមន្ត្រីអំពីការវិវត្តន៍នៃសភាពការណ៍នៅតំបន់ ប៉ះពាល់ និងស្នើសុំការណែនាំតាមការចាំបាច់ពីសម្តេចនាយករដ្ឋមន្ត្រី ។

**ប្រការ ៤** : ក្រុមការងារមានសិទ្ធិបង្កើតលេខាធិការដ្ឋានមួយ ដែលមានមុខងារជាសេនាធិការជូនក្រុមការងារ ដើម្បីធ្វើទំនាក់ទំនងជាអចិន្ត្រៃយ៍ជាមួយក្រុមអ្នកសង្កេតការណ៍ឥណ្ឌូនេស៊ី និងដោះស្រាយការងារតាមការជាក់ស្តែង ។

**ប្រការ ៥** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមី ខ្លួនដូចមានចែងក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

*រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កុម្ភៈ ឆ្នាំ ២០១១*

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល</u> :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៥
- ឯកសារ-កាលប្បវត្តិ